# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៤៣...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែប្រែនិងដំឡើងបៀវត្សប្រចាំខែនិងការឧបត្ថម្ភផ្សេងៗសម្រាប់ មន្ត្រីរាជការនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០២/០០១ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការការបរទេស
- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- បានឃើញអនុក្រឹត្យលេខ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងនិងការកំណត់បៀវត្សប្រចាំខែនិងការឧបត្ថម្ភផ្សេងៗសម្រាប់មន្ត្រីរាជការនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស
- បានឃើញអនុក្រឹត្យលេខ១០៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១.-**

ត្រូវបានកែប្រែប្រភេទចំណាត់ថ្នាក់ប្រទេសដែលមានស្ថានតំណាងកម្ពុជាតាំងនៅ ដូចខាងក្រោម៖

| លរ | ប្រភេទប្រទេស "ក" | ប្រភេទប្រទេស "ខ" | ប្រភេទប្រទេស "គ" |
|---|---|---|---|
| ១ | **ប្រទេសអូស្ត្រាលីនិងនូវែលសេឡង់**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងកង់បេរ៉ា | **សាធារណរដ្ឋឥណ្ឌា**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងញូវដេលី | |
| ២ | **ព្រះរាជាណាចក្របែលហ្ស៊ិក**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុង ព្រុចសែលនិងស្ថានបេសកកម្ម អចិន្ត្រៃយ៍អមសហគមន៍អឺរ៉ុប | **ព្រុយណេដារូសាឡាម**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុង បានដាសេរីបេហ្គាវ៉ាន់ | |
| ៣ | **ប្រទេសកាណាដា**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងអូតាវ៉ា | **សាធារណរដ្ឋគុយបា**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងឡាហាវ៉ាន | |
| ៤ | **សាធារណរដ្ឋប្រជាមានិតចិន**<br>-ស្ថានឯកអគ្គរាជទូត នៅទីក្រុងប៉េកាំង<br>-ស្ថានអគ្គកុងស៊ុលប្រចាំទីក្រុង ហុងកុងនិងម៉ាកាវ<br>-ស្ថានអគ្គកុងស៊ុល ប្រចាំទីក្រុង សៀងហៃ | - ស្ថានអគ្គកុងស៊ុល ប្រចាំទីក្រុងឆុងឈីង<br>- ស្ថានអគ្គកុងស៊ុល ប្រចាំទីក្រុងគុនមិញ<br>- ស្ថានអគ្គកុងស៊ុល ប្រចាំទីក្រុងណាននីង<br>- ស្ថានអគ្គកុងស៊ុល ប្រចាំទីក្រុងស៊ីអាន<br>- ស្ថានអគ្គកុងស៊ុល ប្រចាំទីក្រុងហៃគូ<br>- ស្ថានអគ្គកុងស៊ុល ប្រចាំទីក្រុងជីងណាន<br>- ស្ថានអគ្គកុងស៊ុល ប្រចាំទីក្រុងក្វាងចូវ | |
| ៥ | **សាធារណរដ្ឋបារាំង**<br>-ស្ថានឯកអគ្គរាជទូត នៅទីក្រុងប៉ារីស<br>-ស្ថានគណៈប្រតិភូអចិន្ត្រៃយ៍ប្រចាំ អង្គការយូណេស្កូ | **សាធារណរដ្ឋឥណ្ឌូណេស៊ី**<br>-ស្ថានឯកអគ្គរាជទូតនៅទីក្រុងហ្សាការតា<br>-ស្ថានតំណាងអចិន្ត្រៃយ៍អមលេខាធិការ-ដ្ឋានអាស៊ាននៅទីក្រុងហ្សាការតា | |
| ៦ | **សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងប៊ែរឡាំង | **សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងព្យុងយ៉ាង | |

| | | | |
|---|---|---|---|
| ៧ | **ប្រទេសជប៉ុន**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងតូក្យូ | **សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**<br>-ស្ថានឯកអគ្គរាជទូត នៅទីក្រុងវៀងចន្ទន៍<br>-ស្ថានអគ្គកុងស៊ុលប្រចាំទីក្រុងប៉ាក់សេ | |
| ៨ | **សាធារណរដ្ឋកូរ៉េ**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងសេអ៊ូល | **ប្រទេសម៉ាឡេស៊ី**<br>-ស្ថានឯកអគ្គរាជទូត នៅទីក្រុងគូឡាឡាំពួ | |
| ៩ | **សហព័ន្ធរុស្ស៊ី**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងម៉ូស្គូ | **សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងយ៉ាងហ្គូន | |
| ១០ | **សហព័ន្ធស្វីស**<br>-ស្ថានបេសកកម្មអចិន្ត្រៃយ៍ ប្រចាំ អង្គការសហប្រជាជាតិ<br>-អង្គការពាណិជ្ជកម្មពិភពលោក និង អង្គការអន្តរជាតិនានា នៅហ្សឺណែវ | **ព្រះរាជាណាចក្រថៃ**<br>-ស្ថានឯកអគ្គរាជទូត នៅទីក្រុងបាងកក<br>-ស្ថានអគ្គកុងស៊ុល ប្រចាំខេត្តស្រះកែវ | |
| ១១ | **ចក្រភពអង់គ្លេស**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងឡុងដ៏ | **សាធារណរដ្ឋសេណេហ្គាល់**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងដាកា | |
| ១២ | **សហរដ្ឋអាមេរិក**<br>-ស្ថានឯកអគ្គរាជទូតនៅទីក្រុង វ៉ាស៊ីនតោន<br>-ស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំ អង្គការសហប្រជាជាតិនៅញូវយ៉ក | **សាធារណរដ្ឋសង្គមនិយមវៀតណាម**<br>-ស្ថានឯកអគ្គរាជទូត នៅទីក្រុងហាណូយ<br>-ស្ថានអគ្គកុងស៊ុល ប្រចាំទីក្រុងហូជីមិញ | |
| ១៣ | **សាធារណរដ្ឋអារ៉ាប់ អេហ្ស៊ីប**<br>-ស្ថានឯកអគ្គរាជទូតនៅទីក្រុងគែរ | **សាធារណរដ្ឋហ្វីលីពីន**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងម៉ានីល | |
| ១៤ | **រដ្ឋកូវ៉ែត**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងកូវ៉ែត | | |
| ១៥ | **សាធារណរដ្ឋសិង្ហបុរី**<br>ស្ថានឯកអគ្គរាជទូត នៅទីក្រុងសិង្ហបុរី | | |
| ១៦ | **សាធារណរដ្ឋប៊ុលហ្គារី**<br>ស្ថានឯកអគ្គរាជទូតនៅទីក្រុងសូហ្វីយ៉ា | | |
| ១៧ | **សាធារណរដ្ឋស៊ែប៊ី**<br>ស្ថានឯកអគ្គរាជទូតនៅទីក្រុងប៊ែលក្រាត | | |
| ១៨ | **សាធារណរដ្ឋតួកគី**<br>ស្ថានឯកអគ្គរាជទូតនៅទីក្រុងអង់ការ៉ា | | |

| | | | |
|---|---|---|---|
| ១៩ | **សាធារណរដ្ឋឆែក**<br>ស្ថានឯកអគ្គរាជទូតនៅទីក្រុងប្រាក | | |
| ២០ | **សាធារណរដ្ឋហុងគ្រី**<br>ស្ថានឯកអគ្គរាជទូតនៅទីក្រុងប៊ុយដាប៉េស | | |

**មាត្រា២ .-**

ដំឡើងបៀវត្សប្រចាំខែរបស់មន្ត្រីនិងបុគ្គលិកដែលបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស ដូចខាងក្រោម៖

ឯកតា៖ គិតជាដុល្លារអាមេរិក

| ល.រ | មុខតំណែង | ប្រភេទប្រទេស | | |
|---|---|---|---|---|
| | | ក | ខ | គ |
| ១ | - ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព | ៣ ៥០០ | ២ ៩០០ | ២ ៨០០ |
| ២ | - តំណាងអចិន្ត្រៃយ៍រង(ឋានៈជាឯកអគ្គរាជទូត) | ៣ ៣០០ | ២ ៩០០ | ២ ៨០០ |
| ៣ | - អគ្គរាជទូត | ៣ ០០០ | ២ ៥០០ | ២ ៣០០ |
| ៤ | - អគ្គទីប្រឹក្សា | ៣ ០០០ | ២ ៤០០ | ២ ៣០០ |
| ៥ | - ទីប្រឹក្សា<br>- អគ្គកុងស៊ុល | ២ ៦០០ | ២ ២០០ | ២ ១០០ |
| ៦ | - លេខាធិការទី១<br>- អនុព័ន្ធជំនាញ | ២ ៥០០ | ២ ០០០ | ១ ៩០០ |
| ៧ | - លេខាធិការទី២<br>- កុងស៊ុល<br>- អនុព័ន្ធជំនាញរង | ២ ៣០០ | ១ ៨០០ | ១ ៧០០ |
| ៨ | - លេខាធិការទី៣ | ២ ២០០ | ១ ៧០០ | ១ ៦០០ |
| ៩ | - អនុព័ន្ធ<br>- អនុកុងស៊ុល/ ភ្នាក់ងារកុងស៊ុល | ២ ២០០ | ១ ៧០០ | ១ ៦០០ |
| ១០ | - គណនេយ្យករ<br>- បុគ្គលិករដ្ឋបាលនិងបច្ចេកទេស | ១ ៧០០ | ១ ៤០០ | ១ ៣០០ |
| ១១ | - បុគ្គលិកសេវា(អ្នកបើកបរនិងអ្នកដាំស្ល) | ១ ៥០០ | ១ ២០០ | ១ ១០០ |

បៀវត្សប្រចាំខែសម្រាប់មន្ត្រីរាជការស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិកម្ពុជា និងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេសដែលបានដំឡើងនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០នេះតទៅ។

**មាត្រា៣ ._**

ដំឡើងប្រាក់ឧបត្ថម្ភឈ្នួលផ្ទះ ជូនមន្ត្រីនិងបុគ្គលិករដ្ឋបាលនិងបច្ចេកទេសដែលមិនមានអគារស្នាក់នៅ ដូចខាងក្រោម៖

ឯកតា៖ គិតជាដុល្លារអាមេរិក

| ល.រ | មុខតំណែង | ប្រភេទប្រទេស | | |
|---|---|---|---|---|
| | | ក | ខ | គ |
| ១ | ចាប់ពីថ្នាក់តំណាងអចិន្ត្រៃយ៍រងដល់ថ្នាក់លេខាធិការទី១ និងថ្នាក់ប្រហាក់ប្រហែល | ១ ៧០០ | ១ ៣០០ | ១ ២០០ |
| ២ | ចាប់ពីថ្នាក់លេខាធិការទី២ដល់ថ្នាក់អនុព័ន្ធ និងថ្នាក់ប្រហាក់ប្រហែល | ១ ៥០០ | ១ ២០០ | ១ ១០០ |
| ៣ | បុគ្គលិករដ្ឋបាលនិងបច្ចេកទេស និងថ្នាក់ប្រហាក់ប្រហែល | ១ ៤០០ | ១ ១០០ | ១ ០០០ |

ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះនេះ មិនអនុវត្តចំពោះបុគ្គលិកសេវាឡើយ។ ប្រាក់ឧបត្ថម្ភឈ្នួលផ្ទះនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តទៅ។

**មាត្រា៤ ._**

ដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនសហព័ទ្ធ និងកូនក្នុងបន្ទុករបស់មន្ត្រីនិងបុគ្គលិកដែលបំពេញភារកិច្ច ដូចមានចែងក្នុងមាត្រា២នៃអនុក្រឹត្យនេះ លើកលែងបុគ្គលិកសេវា ដូចខាងក្រោម៖

- ផ្តល់ប្រាក់ឧបត្ថម្ភចំនួន៣០០(បីរយ)ដុល្លារអាមេរិកក្នុង០១ខែសម្រាប់សហព័ទ្ធ ដោយត្រូវមានសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមកបញ្ជាក់
- ផ្តល់ប្រាក់ឧបត្ថម្ភចំនួន២០០(ពីររយ)ដុល្លារអាមេរិកក្នុង០១ខែ សម្រាប់កូនក្នុងបន្ទុកដែលមានអាយុក្រោម១៨ឆ្នាំដោយត្រូវមានសេចក្តីចម្លងសំបុត្រកំណើតច្បាប់ដើមមកបញ្ជាក់
- ការផ្តល់ប្រាក់ឧបត្ថម្ភកូនរបស់មន្ត្រី និងបុគ្គលិកត្រូវផ្អែកលើមូលដ្ឋាននៃចំនួនកូនដែលមានក្នុងតារាងបៀវត្សក្នុងប្រទេសមុនពេលចាត់តាំងឱ្យទៅបំពេញបេសកកម្មនៅបរទេស។

ប្រាក់ឧបត្ថម្ភសហព័ទ្ធនិងកូននេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តទៅ។

**មាត្រា៥ ._**

កែប្រែសោហ៊ុយធ្វើដំណើរទៅកាន់តំណែងដំបូងនៅបរទេស និងត្រឡប់ចូលប្រទេសពេលចប់អាណត្តិ ដូចខាងក្រោម៖

- ផ្តល់សំបុត្រយន្តហោះថ្នាក់ជំនួញ(Business Class) ជូនឯកអគ្គរាជទូត និងសហព័ទ្ធ ព្រមទាំងកូនក្នុងបន្ទុកដែលមានអាយុក្រោម១៨ឆ្នាំ

- ផ្តល់សំបុត្រយន្តហោះថ្នាក់ធម្មតា(Economy Class) ជូនមន្ត្រីនិងបុគ្គលិកផ្សេងទៀតការផ្តល់សំបុត្រយន្តហោះនេះ ត្រូវអនុវត្តចាប់ពីអនុក្រឹត្យនេះ ចូលជាធរមាន។

**មាត្រា៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ១១ កើត ខែ ... ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

**ប្រាក់ សុខុន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ